ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៤២
ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩
សាលដីកា
លេខ ២៦ "II"
ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០

# សាលដីកា

## នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០
ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. លោកស្រី [redacted] ជាប្រធាន
២. លោក [redacted] ជាចៅក្រម
៣. លោក [redacted] ជាចៅក្រម
៤. លោក [redacted] ជាចៅក្រម
៥. លោកស្រី [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] បានៈជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ១៥១ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុបិន្ត ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២១ ក្រVI "ប.ស" ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ដែលមាន ៖

**- ជនជាប់ចោទ ៖**

១-ឈ្មោះ [redacted] សុបិន្ត ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិកោះលត ឃុំកោះថ្កូវ ស្រុកជល់គីរី ខេត្តកំពង់ឆ្នាំង ទីលំនៅមុនពេលឃុំខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] ទោសពីមុនគ្មាន ។ (ក្នុងឃុំ) (អ្នកប្តឹងសាទុក្ខ)

-មានលោកស្រី [redacted] សុខសួលីដា ជាមេធាវីការពារសិទ្ធិ



Scanned with CamScanner

២-ឈ្មោះ [redacted] ណារិទ្ធ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅភូមិបែកចាន ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ទីលំនៅមុនពេលឃុំខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ។ (ក្នុងឃុំ) (មិនប្តឹងសាទុក្ខ)

- **ជាប់ចោទពីបទ** លួចមានស្ថានទម្ងន់ទោសដោយការកាប់គាស់ទម្លុះទម្លាយ ប្រព្រឹត្តនៅចំណុចសំណង់អគារសង់ថ្មី ផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣-ឈ្មោះ [redacted] កុយ ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរតេម៉ូតូឌុប កើតនៅសង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ពោះម៉ាយ ទោសពីមុនគ្មាន ។ (ក្នុងឃុំ) (មិនប្តឹងសាទុក្ខ)

៤-ឈ្មោះ [redacted] លាងហុង ភេទស្រី អាយុ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មកររោងចក្រ កើតនៅភូមិមិត្តត្រាច ឃុំអំបិលពពក ស្រុកអូររាំងឪ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃុំខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" មេម៉ាយ ទោសពីមុនគ្មាន ។ (ក្នុងឃុំ) (មិនប្តឹងសាទុក្ខ)

- **ជាប់ចោទពីបទ** សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស ដោយការកាប់គាស់ទម្លុះទម្លាយ ប្រព្រឹត្តនៅចំណុចសំណង់អគារសង់ថ្មី ផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៥-ឈ្មោះ [redacted] បុរី ហៅ ពេជ្រ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ កើតនៅសង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ។ (ក្នុងឃុំ) (មិនប្តឹងសាទុក្ខ)

- **ជាប់ចោទពីបទ** ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចសំណង់អគារសង់ថ្មី ផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

- **ដើមបណ្តឹងរដ្ឋប្បវេណី ៖** ឈ្មោះ [redacted] រង្វា ភេទប្រុស អាយុ ២១ឆ្នាំ អាស័យដ្ឋាន [redacted] រាជធានីភ្នំពេញ ។



Scanned with CamScanner

## អង្គហេតុ

កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ០៣: និង៣០នាទីទៀបភ្លឺ នៅចំណុចសំណង់អគារសង់ថ្មី ផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានករណីលួចមានស្ថានទម្ងន់ទោស ដែលបង្កឡើងដោយជនត្រូវចោទឈ្មោះ [redacted] ណារិទ្ធ ឈ្មោះ [redacted] សុបិន្ត និងឈ្មោះ ស៊ិត ដោយពួកគេបានធ្វើសកម្មភាពគាស់ទ្វាររបង ចូលកាត់សោរលួចយកម៉ូតូម៉ាកហុងដា C125 សេរីឆ្នាំ ២០០៨ ពាក់ស្លាកលេខ តាកែវ 1C-8497 មានលេខតួ និងលេខម៉ាស៊ីន 8292395 របស់ជនរងគ្រោះឈ្មោះ [redacted] វង្ឍា ដែលបានចតទុកនៅក្នុងការដ្ឋានសំណង់ខាងលើជិះយកទៅបាត់ ។ បន្ទាប់ពីកើតហេតុជនរងគ្រោះបានដាក់ពាក្យបណ្តឹងមកសមត្ថកិច្ច និងបានបង្ហាញរូបភាពក្នុងកាមេរ៉ាសុវត្ថិភាព ឃើញមានជនសង្ស័យចំនួន ០៣នាក់បានធ្វើសកម្មភាពលួចម៉ូតូ ហើយសមត្ថកិច្ចបានស្រាវជ្រាវរកឃើញមុខសញ្ញាឈ្មោះ [redacted] សុបិន្ត និងធ្វើការឆែកឆេរនៅបន្ទប់ជួលរបស់ឈ្មោះ [redacted] សុបិន្ត ស្ថិតនៅក្នុង [redacted] រាជធានីភ្នំពេញ ឃើញមានដែកកៃច្នៃសម្រាប់កាច់បំផ្លាញមេសោរមួយសម្រាប់ ដែកលួសរឹងកៃច្នៃសម្រាប់ផ្ទះបំផ្លាញមេសោរចំនួន ០៤ បន្ទាប់មកសមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ [redacted] សុបិន្ត និងបក្ខពួកឈ្មោះ [redacted] លាងហុង ឈ្មោះ [redacted] បុរី ហៅ ពេជ្រ នៅផ្ទះរបស់ឈ្មោះ [redacted] សុបិន្ត និងបន្តឃាត់ខ្លួនឈ្មោះ [redacted] ណារិទ្ធ និងឈ្មោះ [redacted] កុយ ឯឈ្មោះ ស៊ិត បានរត់គេចខ្លួនបាត់ ។

សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៦១១ ក្រ៣ "ន" ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ ៖

១-ឱ្យជនជាប់ចោទឈ្មោះ [redacted] កុយ ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ រួចខ្លួន ពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយការកាប់គាស់ទម្លុះទម្លាយ ប្រព្រឹត្តនៅចំណុចសំណង់អគារសង់ថ្មី ផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩, មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២-ផ្តន្ទាទោសជនជាប់ចោទ៖

ក-ឈ្មោះ [redacted] សុបិន្ត ភេទប្រុស អាយុ២៧ឆ្នាំ ជានជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ

ខ-ឈ្មោះ [redacted] ណារិទ្ធ ភេទប្រុស អាយុ២០ឆ្នាំ ជានជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ

ពីបទ: លួចមានស្ថានទម្ងន់ទោសដោយការកាប់គាស់ទម្លុះទម្លាយ ប្រព្រឹត្តនៅចំណុចសំណង់អគារសង់ថ្មី ផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

គ-ឈ្មោះ [redacted] ហុង ភេទស្រី អាយុ២២ឆ្នាំ ជានជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ



Scanned with CamScanner

ពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយការកាប់គាស់ទម្លុះទម្លាយ ប្រព្រឹត្តនៅចំណុចសំណង់អគារសង់ថ្មី ផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩, មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

ឃ-ឈ្មោះ [redacted] បូរី ហៅ ពេជ្រ ភេទប្រុស អាយុ២៦ឆ្នាំ ជានជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០២ឆ្នាំ តែអនុវត្តទោសពន្ធនាគារចំនួន០១ឆ្នាំ "មួយឆ្នាំ" ទោសដែលនៅសល់ត្រូវព្យួរជម្មតា ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចសំណង់អគារសង់ថ្មី ផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

៣-វត្ថុចាប់យកៈ

ក.ម៉ូតូ០១គ្រឿង ម៉ាកស្កុបពី ពណ៌ក្រហម បិតស្កុតខ្មៅ ទឹកប្រាក់ លេខតួ ៥០១៣៦៧៥ លេខម៉ាស៊ីន ០០១៨៦៧៥ (គ្មានស្លាកលេខ គ្មានប្រអប់កុងទ័រ គ្មានសោរ) ។

ខ.ម៉ូតូ០១គ្រឿង ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ (លេខតួ និងលេខម៉ាស៊ីនឈូសលុប) ពាក់ស្លាក លេខភ្នំពេញ 1CX-7873 (គ្មានកញ្ចក់ គ្មានសោរ) ។

គ.ម៉ូតូ០១គ្រឿង ម៉ាកវីវ៉ា ពណ៌ខ្មៅ លេខតួ និងលេខម៉ាស៊ីន ៣២២០៥០ ពាក់ស្លាកលេខកំពង់ស្ពឺ 1A-7519 (គ្មានកញ្ចក់ គ្មានសោរ ម៉ូតូចាស់) ។

សម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ តាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ឃ.គ្រាប់កឹបស័ង្កសីមួយចំនួន ដែកកែច្នៃសម្រាប់កាច់កម៉ូតូ ចំនួន០១ ដែកលួសកែច្នៃសម្រាប់ឆ្កឹះ សោរម៉ូតូចំនួន០១ សម្រេចរឹបអូសតាមបញ្ញត្តិមាត្រា៦២ មាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនាថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

សាលក្រមនេះត្រូវបានឈ្មោះ [redacted] ណារិទ្ធ ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៦០៣ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

សាលក្រមនេះត្រូវបានឈ្មោះ [redacted] សុបិន្ត ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៦០៤ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

សាលាឧទ្ធរណ៍បានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ២១ ក្រVI "ប.ស" ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ ៖



Scanned with CamScanner

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៦០៣ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ណារិទ្ធ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៦០៤ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សុបិន្ត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ៦១១ ក្រ៩ "ន" ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៤-បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទនិងឈ្មោះ [redacted] សុបិន្ត និងជនជាប់ចោទឈ្មោះ ធន ណារិទ្ធ ប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ ។

-ទុកសិទ្ធិប្តឹងសាទុក្ខតាមច្បាប់ ។

សាលដីកានេះត្រូវបានឈ្មោះ [redacted] សុបិន្ត ប្តឹងសាទុក្ខតាមបណ្តឹងលេខ ១៥១ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានថា តាមការពិនិត្យរឿងហេតុឃើញថា ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ដែលតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល គឺមានភស្តុតាងនិងសំអាងហេតុត្រឹមត្រូវតាមច្បាប់ ព្រោះថា បក្សពួករបស់ជនជាប់ចោទឈ្មោះ [redacted] ណារិទ្ធ នៅមុខសមត្ថកិច្ចបានឆ្លើយបញ្ជាក់ច្បាស់លាស់ថាឈ្មោះ សឿន សុបិន្ត នេះបានចូលរួមជាមួយខ្លួនដូចមាននៅក្នុងសំអាងចំណុចទី៧ នៃសាលដីការបស់សាលាឧទ្ធរណ៍ស្រាប់។ ការបដិសេធរបស់សាមីខ្លួនគ្រាន់តែជាការដោះសារតែប៉ុណ្ណោះ។ ដូច្នេះតំណាងមហាអយ្យការស្នើសុំតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២១ ក្រVI "ប.ស" ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

- ជនជាប់ចោទឈ្មោះ [redacted] សុបិន្ត បានឆ្លើយថា ខ្លួនមិនសុខចិត្ត ដោយសារតែទោសច្រើនពេក។ នៅយប់ថ្ងៃកើតហេតុខ្លួនបានដេកតាំងពីម៉ោង ៨ រហូតដល់ម៉ោង ៣:៣០ នាទីទៀបភ្លឺ ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ឈ្មោះ ស្វិត បានមកគោះទ្វារបន្ទប់ខ្លួនហើយហៅទៅក្រៅ ខ្លួនបានឃើញម៉ូតូ ២គ្រឿង តែមិនបានដឹងថាពួកគេលួចមកពីណាទេ។ ហើយឈ្មោះ ស្វិត បានឱ្យខ្លួនជួយជិះម៉ូតូមួយទៅផ្ទះគេ ពេលខ្លួនជិះបានប្រហែល៥០ម៉ែត្រ ឈ្មោះ ស្វិត ក៏បានឱ្យខ្លួនឈប់ម៉ូតូ ហើយឱ្យខ្លួនចូលទៅដេកវិញ។ ខ្លួនមិនបានចូលរួមលួចម៉ូតូនោះទេ ខ្លួនសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង។

- លោកស្រីមេធាវី [redacted] សុខសូលីដា បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានធ្វើការពិភាក្សាដេញដោលហើយ ឃើញថាកូនក្តីរបស់ខ្លួនឈ្មោះ [redacted] សុបិន្ត បានឆ្លើយបញ្ជាក់ជូនក្រុមប្រឹក្សាជំនុំជម្រះរួច



Scanned with CamScanner

ហើយថាខ្លួនគាត់ពុំបានចូលរួមប្រព្រឹត្តសកម្មភាព កាប់គាស់ទម្លុះទម្លាយ យកម៉ូតូគេចេញពីកន្លែងកើតហេតុទេ។ ប៉ុន្តែជាកំហុសមួយដែលគាត់បានជួយជិះម៉ូតូ ឈ្មោះស៊ិត យកចេញទៅក្រៅ ហើយគាត់មិនបានសួរថា ម៉ូតូនោះបានមកពីណានោះទេហើយគាត់បានបញ្ជាក់ហើយថាគាត់មិនទទួលផល នៃអំពើនោះដែរ។ ក្នុងនោះកូនក្តីខ្លួនឈ្មោះ [redacted] សុបិន្ត តាំងពីដំណាក់កាលសាលាដំបូងមកគឺគាត់បានឆ្លើយក សារភាពរហូតមក ហើយនៅក្នុងកំណត់ហេតុឆ្លើយរបស់ [redacted] ណារិទ្ធ ក៏បានបញ្ជាក់ដែលថាគាត់បានលួចម៉ូតូ ពីរនាក់ឈ្មោះ ស៊ិត ហើយ ស៊ិត ក៏បានសារភាព និងទទួលស្គាល់ថា គាត់បានដឹងអំពីកំហុសគាត់ថា គាត់សេពគប់ មនុស្សខុស និងជួយជិះម៉ូតូគេដោយ មិនបានសួរនាំក៏ខុស។ ដូច្នេះ បើយោងតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិពីស្ថានសម្រាល កាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវតុលាការ អាចសម្រេចឱ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលបាន។ នៅក្នុងអង្គហេតុ ឃើញថាកូនក្តីខ្លួន គាត់បានប្រព្រឹត្តខុស បន្តិចបន្តួចមែន ក៏ប៉ុន្តែគាត់បានឆ្លើយសារភាព តាំងពីដំណាក់កាលសាលាដំបូង ក៏ដូចជាសាលាឧទ្ធរណ៍មិនបានពិចារណា ស្ថានសម្រាលជូនគាត់នោះទេ។ ហេតុដូច្នេះខ្លួនស្នើសុំប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាលើ ស្ថានសម្រាលទោសឱ្យកូនក្តីខ្លួនផង។

## តុលាការកំពូល

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៥១ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុបិន្ត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ជនជាប់ចោទ បានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ នៅថ្ងៃកើតហេតុខ្លួន នៅបន្ទប់ជួលរបស់សង្សារខ្លួន មិនបានទៅណាទេ ហើយចំពោះចម្លើយនៅសមត្ថកិច្ចនគរបាលមានការបង្ខិតបង្ខំ ធ្វើទារុណកម្មឱ្យផ្តិតមេដៃទទួលកំហុស។ ការអះអាងរបស់ជនជាប់ចោទនេះពុំមានភស្តុតាងបញ្ជាក់ទេ ផ្ទុយទៅវិញ តាមចម្លើយរបស់ជនជាប់ចោទ នៅមន្ត្រីនគរបាលយុត្តិធម៌ បានរៀបរាប់យ៉ាងច្បាស់លាស់ពីអំពើប្រព្រឹត្តរបស់ខ្លួន ដូចនេះ តាមមាត្រា ១១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កំណត់ហេតុនេះត្រូវបានទុកជាភស្តុតាងដែលជឿរហូតមានភស្តុតាងផ្ទុយ។



Scanned with CamScanner

លើសពីនេះទៅទៀត តាមចម្លើយរបស់បក្សពួកឈ្មោះ [redacted] សុបិន្ត ក៏បានបញ្ជាក់ថា ឈ្មោះ [redacted] សុបិន្ត បានចូលរួមធ្វើសកម្មភាពដែរ។

៣-យល់ឃើញថា បណ្ដឹងសា ទុក្ខរបស់ជនជាប់ចោទ មិនមានមូលហេតុដូចការកំណត់នៃមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២១ ក្រVI "ប.ស" ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ដែលសម្រេចមកនេះ ត្រឹមត្រូវហើយ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដី**

១-បដិសេធបណ្ដឹងសាទុក្ខលេខ ១៥១ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុបិន្ត។

២-តម្កល់សាលដីកាព្រហ្មទណ្ឌ លេខ ២១ ក្រVI "ប.ស" ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទាំងមូល។

*សាលដីកានេះ បានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ និងប្រកាសសនាសវនាការជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០។*

Scanned with CamScanner